# ស្ថានភាពសុខភាព និងវ័យចាស់ជរា កំពុងរារាំង អៀង សារី មិនឱ្យ
# ទិលត្រឡប់ចូលរួមសវនាការជំនុំជម្រះក្តីលើរូបខ្លួន

***លីម ជ័យទ័ត្ត***
***អ្នកសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម***
***មជ្ឈមណ្ឌលឯកសារកម្ពុជា***

*នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបើកសវនាការដាច់ដោយឡែកមួយ ដោយអញ្ជើញវេជ្ជបណ្ឌិតពីររូបពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដើម្បីសាកសួរអំពីស្ថានភាពសុខភាពជនជាប់ចោទ អៀង សារី ដែលត្រូវបានបញ្ជូនចូលព្យាបាលជាបន្ទាន់នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត កាលពីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១២ ។*

*អង្គជំនុំជម្រះបានជូនដំណឹងថា សវនាការនេះធ្វើឡើងក្នុងគោលបំណងដើម្បីចង់ដឹងអំពីការវិវឌ្ឍនៃស្ថានភាពសុខភាពរបស់ អៀង សារី ថាតើជនជាប់ចោទរូបនេះអាចចូលរួមនៅក្នុងសវនាការបានដែរឬយ៉ាងណា ។ បន្ទាប់មកនៅរសៀលថ្ងៃដដែល អង្គជំនុំជម្រះបានបើកសវនាការមួយទៀតទាក់ទងនឹងការផ្តល់សក្ខីកម្មរបស់អ្នកជំនាញ ហ៊ូលីព ស៊ិត នៅស្របពេលដែលជនជាប់ចោទ អៀង សារី កំពុងស្ថិតនៅក្នុងភាពមិនច្បាស់លាស់ក្នុងការចូលរួមក្នុងសវនាការ ។ អង្គជំនុំជម្រះបានស្នើឲ្យភាគីទាំងអស់ក្នុងសវនាការបង្ហាញអំពីការយល់ឃើញរបស់ខ្លួនចំពោះសវនាការសួរដេញដោលអ្នកជំនាញ ហ៊ូលីព ហ៊ិត នៅក្នុងករណីជនជាប់ចោទ អៀង សារី មិនអាចចូលរួមសវនាការនៅអំឡុងពេលនៃការសួរដេញដោលអ្នកជំនាញរូបនេះ ។*

## ***ការពិភាក្សាអំពីបញ្ហាសុខភាពជនជាប់ចោទ អៀង សារី***

*លោកវេជ្ជបណ្ឌិតលីម ស៊ីវុត្ថា និងលោកវេជ្ជបណ្ឌិត គី ប៊ូស្ស ដែលបម្រើការងារនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ត្រូវបានអង្គជំនុំជម្រះអញ្ជើញមកផ្តល់សក្ខីកម្មទាក់ទងនឹងស្ថានភាពសុខភាពរបស់ជនជាប់ចោទ អៀង សារី នៅក្នុងសវនាការ ។ វេជ្ជបណ្ឌិតទាំងពីររូប គឺជាវេជ្ជបណ្ឌិតដែលស្ថិតនៅក្នុងចំណោមវេជ្ជបណ្ឌិតជាច្រើនរូបផ្សេងទៀតដែលទទួលភារកិច្ចពិនិត្យព្យាបាលជំងឺរបស់ អៀង សារី នៅមន្ទីរទេព្យមិត្តភាពខ្មែរ- សូវៀត ។*

ប្រធានអង្គជំនុំជម្រះ លោកចៅក្រម និល ណុន បានស្នើលោកវេជ្ជបណ្ឌិតលឹមស៊ីវុត្ថា រៀបរាប់អំពីស្ថានភាពសុខភាពរបស់ អៀង សារី ចាប់តាំងពីពេលដែលជនជាប់ចោទរូបនេះត្រូវបាននាំចូលសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១២ រហូតដល់ថ្ងៃសវនាការ ។ លោកវេជ្ជបណ្ឌិត ស៊ីវុត្ថា បានបញ្ជាក់ថា មូលហេតុដែលនាំឲ្យ អៀង សារី ត្រូវចូលសម្រាកក្នុងមន្ទីរពេទ្យជាបន្ទាន់ នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១២ គឺដោយសារជំងឺហេវហត់ ។ លោកបន្តថា ចំពោះស្ថានភាពជំងឺបេះដូង និងសរសៃឈាមរបស់អៀង សារី មិនមានអ្វីប្រែប្រួលទេ ប៉ុន្តែឆ្អឹងកងកកំពុងមានបញ្ហា ដែលធ្វើឲ្យឈាមរត់ទៅចិញ្ចឹមខួរក្បាលមិនគ្រប់គ្រាន់ ដែលជាហេតុបណ្តាលឲ្យមានការស្ពឹកចុងដៃចុងជើង ។

ឆ្លើយតបនឹងសំណួររបស់ចៅក្រមទាក់ទងនឹងស្ថានភាពជំងឺ ហត់ និងវិលមុខរបស់ អៀង សារី លោកវេជ្ជបណ្ឌិតបានអះអាងថា បញ្ហានេះកើតឡើងដោយសារមូលហេតុខ្សោយបេះដូង និងវ័យចាស់ជរា ហើយមិនមានសញ្ញាណាមួយដែលថាជំងឺនេះនឹងអាចវិលមករកស្ថានភាពធូរស្រាលទេ គ្រាន់តែវិវឌ្ឍទៅមុខដោយយឺតៗតែប៉ុណ្ណោះ ។ លោកវេជ្ជបណ្ឌិតបន្តថា អ្វីដែលធ្វើឲ្យលោកមានការព្រួយបារម្ភខ្លាំងបំផុតនោះ គឺជំងឺវិលមុខដែលកើតឡើងដោយសារការគៀបសរសៃឈាមនៅត្រង់ឆ្អឹងកងករបស់ អៀង សារី ដែលជាមូលហេតុចំបងធ្វើឲ្យ អៀង សារី ត្រូវសម្រាកព្យាបាល និងតាមដានស្ថានភាពសុខភាពនៅមន្ទីរពេទ្យបន្តទៀត ។

ក្រោយពីពិគ្រោះជាមួយវេជ្ជបណ្ឌិតជំនាញខាងផ្នែកសរសៃប្រសាទ និងផ្នែកវះកាត់រួមមក លោកវេជ្ជបណ្ឌិត ស៊ីវុត្ថា បានជម្រាបជូនអង្គជំនុំជម្រះថា អៀង សារី ត្រូវចំណាយពេលព្យាបាលនៅមន្ទីរពេទ្យយ៉ាងហោចណាស់មួយខែបន្តទៀត ប្រសិនបើប្រើប្រាស់មធ្យោបាយវះកាត់ផ្លាស់ប្តូរទិសដៅសរសៃឈាមនៅត្រង់ឆ្អឹងកងក និងចំណាយពេលយូរជាងនេះប្រសិនបើព្យាបាលដោយប្រើប្រាស់ថ្នាំ ។ លោកបានសង្កត់ធ្ងន់ថា ការព្យាបាលដោយប្រើប្រាស់មធ្យោបាយវះកាត់អាចប្រឈមមុខនឹងភាពប្រថុយប្រថានខ្ពស់ ដោយសារអៀង សារី កំពុងមានជំងឺពុកឆ្អឹង និងមិនអាចទ្រាំទ្រចំពោះការវះកាត់ដោយប្រើថ្នាំសន្លប់បាន ។ លោកបានបញ្ជាក់ថា ស្ថានភាពជំងឺរបស់ អៀង សារី នាពេលនេះមិនទាន់អាចឲ្យគ្រូពេទ្យធ្វើការវះកាត់បាននៅឡើយទេ ប៉ុន្តែលោកវេជ្ជបណ្ឌិត និងគ្រូពេទ្យជំនាញផ្សេងៗទៀតកំពុងសិក្សាដើម្បីរកដំណោះស្រាយ ។

ឆ្លើយតបនឹងសំណួររបស់ចៅក្រមដែលសួរថា តើប្រភេទនៃការព្យាបាលបែបណាដែលល្អ ហើយមិនចាំបាច់ធ្វើការវះកាត់? លោកវេជ្ជបណ្ឌិត ស៊ីវុត្ថា បានអះអាងថា គឺមានភាគរយតិចតួចប៉ុណ្ណោះដែលរំពឹងថាស្ថានភាពជំងឺរបស់ អៀង សារី នឹងល្អប្រសើរមកវិញ ។ លោកបានបន្ថែមថា ការប្រើប្រាស់ថ្នាំដើម្បី

ព្យាបាល គឺមានលទ្ធភាពតិចតួចតែប៉ុណ្ណោះដែលថានឹងអាចព្យាបាលជំងឺនេះឲ្យជាសះស្បើយ ។ ការវះកាត់ជាជម្រើសដែលល្អ ជាជាងការប្រើប្រាស់ថ្នាំ ប៉ុន្តែការវះកាត់នេះត្រូវមានការសិក្សា និងពិភាក្សាលម្អិត ។

លោកវេជ្ជបណ្ឌិតបានសន្និដ្ឋានថា នៅក្នុងរយៈខ្លី លោកមិនរំពឹងថាជនជាប់ចោទ អៀង សារី នឹងអាចវិលត្រឡប់មកចូលរួមនៅក្នុងសវនាការបានទេ ដោយសារការព្យាបាលបញ្ហាឆ្អឹងកងកត្រូវចំណាយពេលច្រើនខែ ប៉ុន្តែលោក និងវេជ្ជបណ្ឌិតផ្សេងៗទៀត នឹងខិតខំរកមធ្យោបាយដើម្បីព្យាបាលជាប់ចោទ អៀង សារី ឲ្យអាចមានលទ្ធភាពវិលត្រឡប់ចូលរួមនៅក្នុងសវនាការឲ្យបានឆាប់ ។

**គួរកត់សម្គាល់ថា** មេធាវីអន្តរជាតិការពារក្តី អៀង សារី គឺលោក ម៉ៃឃើល កាណាវ៉ាស បានសាកសួរលោកវេជ្ជបណ្ឌិត ស៊ីរ៉ុត្តា អំពីស្ថានភាពសុខភាពរបស់កូនក្តីរបស់ខ្លួន ដោយបង្ហាញថាស្ថានភាពជំងឺវិលមុខរបស់ជនជាប់ចោទ អៀង សារី នឹងធ្វើឲ្យប៉ះពាល់ដល់ការផ្ចង់អារម្មណ៍ ហើយមិនអាចណែនាំមេធាវីការពារក្តីរបស់ខ្លួនដោយប្រសិទ្ធភាពនៅក្នុងសវនាការ ។ ប៉ុន្តែលោកវេជ្ជបណ្ឌិតអះអាងថា បើតាមការយល់ឃើញរបស់លោក ជំងឺវិលមុខរបស់អៀង សារី មិនទាន់មានការប៉ះពាល់ដល់ការផ្ចង់អារម្មណ៍ទេ ។ ទោះបីជាយ៉ាងណាក្តី លោកវេជ្ជបណ្ឌិតបានទទួលស្គាល់ថា លោកមិនអាចបញ្ជាក់អំពីការផ្ចង់អារម្មណ៍នេះបានទេ ដោយសារមិនមែនជាជំនាញរបស់លោក ហើយលោកទុកការវាយតម្លៃអំពីការផ្ចង់អារម្មណ៍ឲ្យអ្នកជំនាញខាងវិកលវិទ្យាជាអ្នកតាមដាន ។

ពាក់ព័ន្ធនឹងសវនាការស្តីពីមតិយោបល់របស់ភាគីចំពោះការចូលរួមរបស់ អៀង សារី នៅក្នុងសវនាការសួរដេញដោលអ្នកជំនាញ ហ៊ីលីព ស៊ីត ទាំងភាគីសហព្រះរាជអាជ្ញា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តីទាំងបីក្រុម បានស្នើសុំអង្គជំនុំជម្រះឲ្យពន្យាពេលសវនាការសួរដេញដោលអ្នកជំនាញហ៊ីលីព ស៊ីត រហូតដល់ឆ្នាំ២០១៣ ។ ភាគីទាំងអស់បានយល់ឃើញស្របគ្នាថា ស្ថានភាពសុខភាពជនជាប់ចោទ អៀង សារី នៅពេលបច្ចុប្បន្ននឹងមិនអនុញ្ញាតឲ្យជនជាប់ចោទរូបនេះអាចចូលរួមនៅក្នុងសវនាការស្តីពីការសាកសួរដេញដោលអ្នកជំនាញ ហ៊ីលីព ស៊ីត បានទេ ។

អង្គជំនុំជម្រះនឹងចេញអនុស្សរណៈមួយស្តីពីបញ្ហាចូលរួមរបស់ជនជាប់ចោទ អៀង សារី នៅក្នុងសវនាការសួរដេញដោលអ្នកជំនាញនេះនៅដើមសប្តាហ៍ក្រោយ ថាតើគួរធ្វើសវនាការសួរដេញដោលអ្នកជំនាញ ហ៊ីលីព ស៊ីត តាមការកំណត់ ឬត្រូវពន្យាពេលសវនាការនេះរហូតដល់ឆ្នាំ២០១៣ ។